ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី២ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី២ សម្រាប់ឆ្នាំ២០១៧ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួន៣៥រូប។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីបង្ហាញពីរបាយការណ៍វឌ្ឍនភាព សមិទ្ធផល និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញពីក្រុមប្រឈមមុខខ្ពស់ទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជា

-កិច្ចពិភាក្សាលើរបាយការណ៍ពីបញ្ហាអេដស៍ សម្រាប់ផ្ញើជូនទៅអង្គការសហប្រជាជាតិ

-បញ្ហាផ្សេងៗ

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក-សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។





**<u>ប្រធានបទទី១</u>៖ ឯកឧត្តមវេជ្ជបណ្ឌិត ខាង ឆោ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេប របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើក្នុងខែមីនា ឆ្នាំ២០១៧ ដូចខាងក្រោម៖

- ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ នៅសណ្ឋាគារមណ្ឌលគីរី ខេត្តមណ្ឌលគីរី អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំបើកសិក្ខាសាលាពិគ្រោះយោបល់លើការងារដែលបានអនុវត្តនៅក្នុងឆ្នាំ២០១៦ និង ពិនិត្យពិភាក្សាផែនការសម្រាប់ឆ្នាំ២០១៧ ក្រោមអធិបតីភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីពិនិត្យមើលឡើងវិញនូវវឌ្ឍនភាព កង្វះខាត បញ្ហាប្រឈម លទ្ធផលការងារក្នុងឆ្នាំ២០១៦ និងពិនិត្យពិភាក្សាផែនការលម្អិតសម្រាប់អនុវត្តក្នុងឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ឯកឧត្តមប្រធានបានមានប្រសាសន៍បញ្ជាក់ក្រើនរំលឹកដល់ថ្នាក់ដឹកនាំ និងមន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបំពេញភារកិច្ចឱ្យទទួលបានប្រសិទ្ធភាព និងជោគជ័យបន្ថែមទៀត អោយស្របទៅនឹងអាណត្តិ និងការទទួលខុសត្រូវរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គឺត្រូវបំពេញការកិច្ច សម្របសម្រួល អន្តរក្រសួង-ស្ថាប័ន នៅគ្រប់កំរិតរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលផ្តល់ជាលទ្ធផលជាក់ស្តែងក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍ អត្រាស្លាប់ដោយសារជំងឺអេដស៍ និងការរើសអើងជាមួយអ្នករស់នៅជាមួយមេរោគអេដស៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជួបប្រជុំជាមួយអគ្គនាយកវិទ្យុជាតិកម្ពុជា ដើម្បីសម្របសម្រួល ក្នុងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមអ្នកកាសែត សារព័ត៌មាន វិទ្យុ និងទូរទស្សន៍ នៅខេត្តព្រះសីហនុ ដែលនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០១៧ និងពិនិត្យមើលលទ្ធភាពសម្របសម្រួលក្នុងការជួយផ្សព្វផ្សាយសារអប់រំស្តីពីមេរោគអេដស៍ក្នុងពិធីបុណ្យជាតិនានាក្នុងវិទ្យុ និងទូរទស្សន៍ជាតិ។

- ពិនិត្យ និងប្រមូលទិន្នន័យទាក់ទងទៅនឹងចំនួនអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ នៅខណ្ឌចំនួន៤ ក្នុងរាជធានីភ្នំពេញរួមមាន៖ ខណ្ឌចំការមន ខណ្ឌដូនពេញ ខណ្ឌទួលគោក និងខណ្ឌមានជ័យ។

- បានចូលរួមប្រជុំពិភាក្សាលើពង្រាងគោលការណ៍ណែនាំពីវិធីសាស្ត្រ និងការអនុវត្តន៍ទាំងឡាយស្តីពីការប្រុងប្រយ័ត្នជាសកល ចំពោះការចម្លងមេរោគអេដស៍ រួមមានការប្រុងប្រយ័ត្នការចម្លងមេរោគអេដស៍ទៅអ្នកជំងឺ និងការប្រុងប្រយ័ត្នការចម្លងទៅអ្នកផ្តល់សេវា។

- បន្តបំពេញរបាយការណ៍វឌ្ឍនភាពឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ (GARPR) ឆ្នាំ២០១៧ សម្រាប់ផ្ញើជូនអង្គការសហប្រជាជាតិ។ ជាលទ្ធផលយើងបានទទួលទិន្នន័យពីស្ថាប័នចំនួនបី ក្នុងចំណោមស្ថាប័នប្រាំដែលត្រូវផ្តល់។

- បានរៀបចំកិច្ចប្រជុំពិភាក្សាលើការដាក់បញ្ចូលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពជាមួយក្រសួងមហាផ្ទៃ និងដៃគូពាក់ព័ន្ធ។ ជាលទ្ធផល សម្រេចរៀបចំលិខិតស្នើសុំទៅ **សម្តេចក្រឡាហោមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដើម្បីសុំការអនុញ្ញាតជួបពិភាក្សា ពិគ្រោះយោបល់ជាមួយមន្ត្រីជំនាញ ដើម្បីសរសេរ Aid Memoire ស្តីពីតម្រូវការនានាដែលចាំបាច់ត្រូវដាក់បញ្ចូលបញ្ហាអេដស៍ ទៅក្នុងគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ។

- ពីថ្ងៃទី១៤-១៧ ខែមីនា ឆ្នាំ២០១៧ បានចុះអភិបាលកិច្ចថ្នាក់ក្រោមជាតិ ស្តីពីការបង្កបរិយាកាសអំណោយផល និងការអនុវត្តន៍កម្មវិធីដៃគូសហគមន៍ សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់នៅឃុំ និងសង្កាត់ ក្នុងខេត្តកោះកុង ដោយបានជួបជាមួយមន្ទីរសុខាភិបាល មន្ទីរផែនការ ឃុំ សង្កាត់ និងអង្គការ CWPD និង MHC។ តាមរយៈការចុះអភិបាល យើងឃើញថាឃុំ សង្កាត់ មិនទាន់ក្តាប់បានពីបញ្ហាអេដស៍ និងក្រុមប្រឈមមុខខ្ពស់ ឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ។
- បានរៀបចំប្រជុំលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដោយបានសម្រេចរៀបចំរបាយការណ៍ប្រចាំឆ្នាំ ២០១៦ របស់ក្រុមការងារ និងឯកភាពលើរបៀបវារៈសម្រាប់កិច្ចប្រជុំប្រចាំត្រីមាសទីមួយឆ្នាំ ២០១៧។
- ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំស្តីពីការប៉ាន់ប្រមាណការចំណាយលើការងារអេដស៍ ដើម្បីពិនិត្យមើលលើរបាយការណ៍ការចំណាយលើការងារអេដស៍លើកទី៥ ឆ្នាំ២០១៤-២០១៥ (NASA V) ។ ជាលទ្ធផលគឺបានពិនិត្យ និងផ្តល់យោបល់កែសម្រួលអនុសាសន៍ ដោយត្រូវការបន្ថែមថា ការប៉ាន់ប្រមាណការចំណាយលើការងារអេដស៍លើកទី៦ ត្រូវចាត់ថ្នាក់ការចំណាយស្របទៅតាមយុទ្ធសាស្ត្រទាំង៦ របស់ផែនការយុទ្ធសាស្ត្រជាតិលើកទី៤ នឹងត្រូវបញ្ចប់របាយការណ៍នៅមួយសប្តាហ៍បន្ទាប់ និងផ្ញើឯកសារអេឡិចត្រូនិចដល់អ្នកពាក់ព័ន្ធ។ ចំពោះសិក្ខាសាលាផ្សព្វផ្សាយនឹងត្រូវធ្វើនៅចុងខែមេសា ឆ្នាំ២០១៧។

**<u>ផែនការសកម្មភាព និងទិសដៅបន្ត៖</u>**

- បន្តធ្វើការទំនាក់ទំនងទៅក្រសួងព័ត៌មាន ក្នុងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ ដល់អ្នកកាសែត សារព័ត៌មាន វិទ្យុ ទូរទស្សន៍ នៅខេត្តព្រះសីហនុ ដែលនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០១៧ ។
- បន្តការងារប្រមូលទិន្នន័យពីស្ថាប័នពាក់ព័ន្ធ ដូចជា មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងក្រសួងកិច្ចការនារី សម្រាប់ធ្វើរបាយការណ៍វឌ្ឍនភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៧ (GARPR 2017)ផ្ញើជូនទៅអង្គការសហប្រជាជាតិ ។
- បន្តការងារបញ្ចប់របាយការណ៍ស្តីពីការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍លើកទី៥(NASA V) និងត្រូវផ្ញើជូនដល់អ្នកពាក់ព័ន្ធ។
- បញ្ចប់កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៨-២០២០ ដែលនឹងត្រូវផ្ញើជូនទៅក្រសួងផែនការ។
- ចុះអភិបាលកិច្ចលើការអនុវត្តន៍ការងារប្រយុទ្ធនឹងជំងឺអេដស៍ និងការបង្កបរិយាកាសអំណោយផលនៃការអនុវត្តន៍កម្មវិធីដៃគូសហគមន៍ សម្រាប់ប្រជាជនប្រឈមមុខខ្ពស់ នៅតាមខេត្តនានា។
- ចូលរួមរៀបចំកិច្ចប្រជុំលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ និងរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រចាំខែ និងត្រីមាស។

- តាមដាន និងពិនិត្យរាល់ការអនុវត្តន៍សកម្មភាពឆ្លើយតបទៅនឹងការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ របស់រាជធានី-ខេត្ត និងស្ថាប័នពាក់ព័ន្ធ។
- បន្តតាមដានការងារទាក់ទងទៅនឹងទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ របស់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងខេត្តគោលដៅចំនួន៨ ដើម្បីពិនិត្យ និងរៀបចំប្រមូលទិន្នន័យសម្រាប់ផ្ញើទៅក្រសួងផែនការ។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានធ្វើកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**តំណាងក្រសួងការពារជាតិ៖** ការិយាល័យអេដស៍ បានចុះអភិបាលកិច្ចនៅសាលានាយទាហានសកម្មត្បាតពងជារៀងរាល់ខែ ទៅតាមកម្មវិធី ហ្វឹកហ្វឺនរបស់សាលា ដោយបញ្ចូលមេរៀនស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺគ្រុនចាញ់ ដល់សិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល។

សំណូមពរៈ សុំជារូបភាព ផ្ទាំងរូបភាព ស្តីពីការបង្ការទប់ស្កាត់មេរោគអេដស៍ ស្រោមអនាម័យ សម្រាប់ផ្តល់ឱ្យគិលានដ្ឋានរបស់សាលា ដើម្បីចែកជូនដល់សិក្ខាកាមពេលគាត់ឈប់សម្រាករៀនសូត្រ ចេញក្រៅសាលា។

**តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច៖** បានចុះផ្សព្វផ្សាយច្បាប់ស្តីពីគ្រឿងញៀននៅស្រុកលើកដែក ខេត្តកណ្តាល ហើយក៏បានបញ្ជ្រាបពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ដល់អ្នកចូលរួមផងដែរ។

**ប្រធានបទទី២៖ ឯកឧត្តម វេជ្ជបណ្ឌិត ហោ ប៊ុនឡេង** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីក្រុមប្រឈមខ្ពស់នឹងការឆ្លង និងចម្លងមេរោគអេដស៍នៅកម្ពុជា៖

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តធ្វើដំណើរឆ្ពោះទៅរកបីសូន្យនៅត្រឹមឆ្នាំ២០២៥គឺៈគ្មានការឆ្លងមេរោគអេដស៍ថ្មី គ្មានការស្លាប់ដោយជំងឺអេដស៍ និងគ្មានការរើសអើងលើអ្នកជំងឺអេដស៍។

មានក្រុមប្រជាជនដែលអត់ប្រឈមនឹងការឆ្លង និងចម្លងមេរោគអេដស៍ និងមានក្រុមប្រជាជនដែលប្រឈមនឹងការឆ្លង និងចម្លងមេរោគអេដស៍ ដែលក្នុងនោះគឺជាក្រុមប្រជាជនដែលមានបុគ្គលិកលក្ខណៈ ឬបែបបទនៃការរស់នៅ ឬការប្រព្រឹត្តក្រោមបរិយាកាសសង្គមសេដ្ឋកិច្ច។ល។ ដែលងាយនឹងទទួលការឆ្លង ឬចម្លងមេរោគអេដស៍។

ក្រុមប្រជាជនដែលប្រឈមនឹងការឆ្លង និងចម្លងមេរោគអេដស៍ ចែកចេញជា៖

-ក្រុមប្រជាជនដែលបានប្រឈមទៅនឹងផ្លូវចម្លងលើសពីមួយដែលមេរោគអេដស៍មានលទ្ធភាពចម្លងខ្ពស់។

-ក្រុមប្រជាជនដែលបានប្រឈមទៅនឹងផ្លូវចម្លងតែមួយ ដែលមេរោគអេដស៍មានលទ្ធភាពចម្លងខ្ពស់។

-ក្រុមប្រជាជនដែលបានប្រឈមទៅនឹងផ្លូវចម្លងតែមួយ ដែលមេរោគអេដស៍មានលទ្ធភាពចម្លងទាប។

យោងតាមព័ត៌មានស្តីពីអត្រាផ្ទុកមេរោគអេដស៍ ក្រុមប្រជាជនដែលប្រឈមខ្ពស់នឹងការឆ្លង និងចម្លងមេរោគអេដស៍គឺៈក្រុមអ្នកចាក់គ្រឿងញៀន ក្រុមបុរសស្រឡាញ់បុរស និងក្រុមស្ត្រីគ្រឹះស្ថានកំសាន្តសប្បាយ។

**ប្រធានបទទី៣៖ លោកវេជ្ជបណ្ឌិត លី ចាន់រ៉ាឌុច** អនុប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើការពិភាក្សាលើរបាយការណ៍ពីបញ្ហាអេដស៍ ជាមួយ សមាជិក-សមាជិកា នៃកិច្ចប្រជុំ ដោយមានការដឹកនាំពីឯកឧត្តមប្រធានអង្គប្រជុំ សម្រាប់ផ្ញើជូនទៅអង្គការ សហប្រជាជាតិ។

បន្ទាប់មកឯកឧត្តមប្រធានអង្គប្រជុំ ក៏បានជម្រាបជូនដល់សមាជិក-សមាជិកានៃអង្គប្រជុំថា ***កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៣ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧*** ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង១៥នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និង ស្និទ្ធស្នាលបំផុត។

**ឧបសម្ព័ន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

បានឃើញ និងឯកភាព
**អគ្គលេខាធិការ**

**ប្រធាននាយកដ្ឋាន**
**ទាក់ទង និងចលនាប្រកបពធនធាន**